# សេចក្តីជូនដំណឹង

## ចំពោះកម្មសិក្សាការីណាដែលកំពុងគិតអំពីការដាក់ពាក្យសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួន

ខែកុម្ភៈឆ្នាំ២០១៨

ការិយាល័យអន្តោប្រវេសន៍ក្រសួងយុត្តិធម៌

តាំងពីមុនមក ក្រសួងយុត្តិធម៌បានផ្តល់សិទ្ធិចូលធ្វើការដល់ជនបរទេស ដែលស្នាក់នៅប្រទេសជប៉ុន ដោយស្របច្បាប់ ហើយពេលដែលជនបរទេសនេះបានដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួនបានលើស ប្រាំមួយខែហើយ។ ក៏ប៉ុន្តែ នៅថ្ងៃទី១៥ខែមករាឆ្នាំនេះ ក្រសួងបានពិនិត្យនិងកែតម្រូវលក្ខខណ្ឌដូចតទៅនេះ។

ជាទូទៅ ចំពោះកម្មសិក្សាការី បើមកដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួន ក្រោយរត់គេចពីកន្លែងសិក្សាបច្ចេកទេសជំនាញ ឬក៏ក្រោយបញ្ចប់កម្មវិធីសិក្សាសាបច្ចេកសេជំនាញ ក្រសួងមិនអនុញ្ញាតឲ្យចូលធ្វើការឡើយ ទោះជាលើសប្រាំមួយខែ ក្រោយពីដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនក៏ដោយ។

(ចំណុចទី១) អាចដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោងជាជនភៀសខ្លួនបាន ក្នុងការបន្តធ្វើការជាកម្មសិក្សាការី។

(ចំណុចទី២) ក្រសួងនឹងអនុញ្ញាតឲ្យចូលធ្វើការ ក្នុងករណីអាចទទួលស្គាល់ជាជនភៀសខ្លួនតាមសន្ធិសញ្ញាស្តីពីជនភៀសខ្លួនកំណត់ ឬ ករណីដែលត្រូវការពិចារណាជាលក្ខណមនុស្សធម៌តាមស្ថានភាពនៃប្រទេសកំណើតរបស់អ្នកដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោននេះ។

ទន្ទឹមនឹងនេះ នៅកន្លែងសិក្សាបច្ចេកទេស ពេលណាដែលមានចម្ងល់ ដូចជាមានអំពើខុសច្បាប់ មិនសមនឹងបទបញ្ញត្តិការសិក្សាបច្ចេកទេសជំនាញ ឬមានការព្រួយបារម្ភក្នុងការបន្តសិក្សាបច្ចេកទេសជំនាញ សូមអញ្ជើញទាក់ទងទៅនឹងអង្គភាពការសិក្សាបច្ចេកទេសជំនាញជនបរទេស ដើម្បីពិគ្រោះយោបល់ (សូមមើល "សៀវភៅកម្មសិក្សាការីបច្ចេកទេសជំនាញ" ចាប់ពីទំព័រទី៦៨ទៅ)។